**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

តុលាការរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៦៤៨

ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩

សាលក្រមលេខៈ ០១ (ឋ)

ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័កព.ស២៥៦៣

ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង២,៣០នាទីរសៀល

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ៖**

-ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

-អ្នកតំណាងដោយអាណត្តិ៖ មេធាវី [redacted] និងមេធាវី [redacted] ការិយាល័យ [redacted]។

**ចុងចម្លើយ៖**

-ឈ្មោះ [redacted] អឿន ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

-អ្នកតំណាងដោយអាណត្តិ៖ គ្មាន។

## អង្គហេតុ និងចំណុចវិវាទ

ក/.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖

ក១.ប្តឹងឱ្យចុងចម្លើយសងប្រាក់ចំនួន៩.០០០(ប្រាំបួនពាន់)ដុល្លារ និងជម្ងឺចិត្តសរុបចំនួន៣.០០០(បីពាន់)ដុល្លារ។

ក២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

ខ/.ដំណើររឿងក្តី និងចំណុចវិវាទ៖

ខ១.ការសង្ខេបរឿងក្តី៖



Scanned with CamScanner

នៅថ្ងៃទី១២/កញ្ញា/២០១៩ ចុងចម្លើយឈ្មោះ [redacted] អឿន ភេទប្រុស បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] សុខា ភេទប្រុស ចំនួន៩០០០ដុល្លារ ដោយសន្យាសងប្រាក់ទៅដើមចោទក្នុងមួយខែ២០០ដុល្លារ រៀងរាល់ខែ ចាប់ពីថ្ងៃទី២០/មេសា/២០១៨ តទៅ តាមកិច្ចសន្យាចុះថ្ងៃទី១២/មីនា/២០១៨ ដល់ថ្ងៃកំណត់ ចុងចម្លើយពុំបានសងឡើយ។

១២.<u>អង្គហេតុដែលគ្មានវិវាទ</u>៖

១/.ចុងចម្លើងឈ្មោះ [redacted] អឿន ភេទប្រុស ទទួលស្គាល់ប្រាក់ជំពាក់ចំនួន៩.០០០ដុល្លារ ពីដើមចោទឈ្មោះ [redacted] សុខា ភេទប្រុស ប្រាកដមែន។

២/.ចុងម្លើយសន្យាសងក្នុងមួយខែ២០០ដុល្លារប្រាកដមែន។

១៣.<u>ចំណុចវិវាទ</u>៖

១/.ចុងចម្លើយពុំមានប្រាក់សងទៅដើមចោទភ្លាមៗនោះទេ សុំសងរម្លោះក្នុងមួយខែ៣០០ដុល្លារ តែឱ្យកាត់ប្រាក់ខែ។

២/.ចុងចម្លើយពុំព្រមសងប្រាក់ជម្ងឺចិត្តចំនួន៣.០០០ដុល្លានោះទេ។

៣/.ដើមចោទ និងចុងចម្លើយមិនឯកភាពគ្នាទេ។

១៤.<u>ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ</u>៖

-ដើមចោទឈ្មោះ [redacted] សុខា ភេទប្រុស បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅដដែល។ខ្លួននៅតែទាមទារប្រាក់ដែលចុងចម្លើយជំពាក់ចំនួន៩.០០០ដុល្លារ និងជម្ងឺចិត្ត៣.០០០ដុល្លារដដែល។ អាស្រ័យហេតុនេះសូមលោកចៅក្រមមេត្តាចេញសាលក្រមតាមការប្តឹងសុំដោយក្តីអនុគ្រោះ។

-ចុងចម្លើយឈ្មោះ [redacted] អឿន ភេទប្រុស បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនពុំមានប្រាក់សងទៅចុងចម្លើយភ្លាមៗនោះទេ ខ្លួនសុខចិត្តសងរម្លោះក្នុងមួយខែចំនួន៣០០ដុល្លា ដោយឱ្យកាត់ប្រាក់ខែរបស់ខ្លួន ចំពោះជម្ងឺចំនួន៣.០០០ដុល្លារ ខ្លួនមិនសុំមិនសងទេ។

១៥.<u>ភស្តុតាងជាឯកសារដែលភាគីបានដាក់ជូនតុលាការ</u>៖

-កិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី១២/មីនា/២០១៨។

## <u>សំអាងហេតុ</u>

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១/.តាមពាក្យបណ្តឹង ចុះថ្ងៃទី១០/កញ្ញា/២០១៩ ប្តឹងសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់ និងជម្ងឺចិត្តមកឱ្យខ្លួន ធ្វើឡើងត្រឹមត្រូវតាមច្បាប់។

២/.តាមការអះអាងរបស់ដើមចោទបានបញ្ជាក់ថាកាលពីថ្ងៃទី១២/មីនា/២០១៨ ចុងចម្លើយឈ្មោះ [redacted] អឿន បានខ្ចីបាក់ពីខ្លួនចំនួន៩.០០០ដុល្លារ ដោយសន្យាសងរម្លោះមកវិញចំនួន២០០ដុល្លាក្នុងមួយខែ ជារៀងរាល់ខែ ចាប់ពីថ្ងៃទី២០/មេសា/២០១៨ តទៅ តាមកច្ចិសន្យាសងប្រាក់ ចុះថ្ងៃទី១២/មីនា/២០១៨ ដល់ថ្ងៃទី២០/មេសា/២០១៨ ដែលត្រូវចុងចម្លើយសងប្រាក់ ចុងចម្លើយមិនបានសងប្រាក់មកខ្លួនសោះ ទោះបីជាខ្លួនព្យាយាមទារជាញឹកញាប់យ៉ាណាក៏ដោយ ហើយចុងចម្លើយគេចវេស រហូតដល់បច្ចុប្បន្ន។



Scanned with CamScanner

៣/.យោងតាមកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី១០/មីនា/២០១៨ រវាងដើមចោទ និងចុងចម្លើយ ឃើញថាចុងចម្លើយបានធ្វើកិច្ចសន្យាសងប្រាក់ទៅដើមចោទចំនួន២០០ដុល្លារ ចាប់ពីថ្ងៃទី២០ ជារៀងរាល់ខែ។ តែចុងចម្លើយមិនបានអនុវត្តតាមកិច្ចសន្យានេះឡើយ។ ហេតុដូចនេះឃើញថាមានភស្តុតាងបញ្ជាក់ត្រឹមត្រូវ។ គប្បីតុលាការពិចារណា និងសម្រេច។

៤/.យោងតាមការអះអាងរបស់ដើមចោទ ការទទួលខុសត្រូវរបស់ភាគីចុងចម្លើយ និងតាមភស្តុតាងជាឯកសារដែលបានដាក់ជូនមកតុលាការ បញ្ជាក់ឲ្យឃើញពីអត្ថិភាពនៃសិទ្ធិដែលដើមចោទបានទាមទារ។ គប្បីតុលាការពិចារណាតាមការទាមទាររបស់ដើមចោទ។

៥/.ចំពោះការទាមទាររបស់ដើមចោទនៅសំណងជម្ងឺចិត្តចំនួន៣.០០០ដុល្លា។ តុលាការយល់ឃើញថាការដែលចុងចម្លើយខ្ចីប្រាក់ពីដើមចោទ ដោយមិនបានសងវិញពិតជានាំឲ្យខូចប្រយោជន៍ដល់ដើមចោទ។ គប្បីតុលាការពិចារណា និងសម្រេច។

៦/.តាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី។

## សេចក្ដីសម្រេចបញ្ចប់

1. ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] សុខា ភេទប្រុស។
2. ឲ្យចុងចម្លើយឈ្មោះ [redacted] អឿន ភេទប្រុស សងប្រាក់ចំនួន៩.០០០ដុល្លារ ឲ្យទៅដើមចោទឈ្មោះ [redacted] សុខា ភេទប្រុស។
3. ឲ្យចុងចម្លើយឈ្មោះ [redacted] អឿន ភេទប្រុស សងជម្ងឺចិត្តចំនួន៤.០០០.០០០រៀល ទៅដើមចោទឈ្មោះ [redacted] សុខា ភេទប្រុស។ ទាមទារលើសពីនេះត្រូវច្រានចោល។
4. ប្រាក់ប្រដាប់ក្ដីទទួលបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ស.ព២៥៦៣ ត្រូវនិងថ្ងៃទី២ ខែមករា ឆ្នាំ២០២០។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល១(មួយ)ខែ គិតចាប់ពីថ្ងៃភាគីបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]